ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



**Work Activities**

ប្រចាំខែសីហា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតង | ១ |
| ២- | សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៤-២០១៦ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកក្កដា ឆ្នាំ២០១៣ | ៥ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល

### សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការកំណត់រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតង

កាលពីថ្ងៃទី៨ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហ-ប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតង ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។

យោងតាមសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ២២៧ ស.ជ.ណ.ផក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ សម្តេចតេជោនាយករដ្ឋមន្ត្រី បានអនុញ្ញាតឲ្យគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ប្រកាសផ្សព្វផ្សាយជាផ្លូវការនូវ “ ចលនាប្រឡងប្រណាំងសហគ្រាសគំរូ ” ប្រសិទ្ធនាមក្រោមឈ្មោះ “ រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតង ” (SamdechTecho Prime Minister Eco-Business Awards) ដែលជាផ្នែកមួយនៃចលនាប្រឡងណាំងទីក្រុងស្អាត។



ក្រោមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានប្រកាសជាផ្លូវការចលនាប្រឡងប្រណាំង “ សហគ្រាសគំរូបុគ្គលគំរូ ” ដោយប្រសិទ្ធនាម “ រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតង ” ក្នុងឱកាសប្រារព្ធទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ “ រួមគិត រួមធ្វើ រួមទទួលខុសត្រូវ ” ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ កន្លងទៅ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ ផ្នែកឯកជន និងយុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជាប្រមាណ ៣០០០នាក់ រួចមកហើយ។

ដូច្នេះដើម្បីដាក់ឲ្យដំណើរការចលនាប្រឡងប្រណាំងនេះប្រកបដោយប្រសិទ្ធភាព គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងនេះឡើង។

ការរៀបចំរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងនេះ ធ្វើឡើងដើម្បីជំរុញផ្នែកឯកជនឲ្យចូលរួមក្នុងការអនុវត្តបៃតង និងភាពស្អាត បង្កើននូវគំនិតច្នៃប្រឌិត និងលើកកម្ពស់សុខុមាលភាពសង្គម នាំកម្ពុជាឆ្ពោះទៅរក " កម្ពុជាស្អាត កម្ពុជាបៃតង " ពិសេសចូលរួមទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដែលមានការបែងចែកប្រកបដោយសមធម៌ និងធានាបាននូវតុល្យភាពផ្នែកសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅកម្ពុជា។ ក្នុងន័យនេះ " រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតង " ធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖

- រង្វាន់នេះនឹងក្លាយជាយន្តការទ្រទ្រង់ និងចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាតតាមរយៈការជំរុញ និងលើកទឹកចិត្តឲ្យមានការអនុវត្តដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់សហគ្រាស ឬបុគ្គលក្នុងវិស័យឯកជនស្របតាមទស្សនទាននៃភាពស្អាត និងបៃតងដែលជាជម្រើសដ៏វៃឆ្លាត និងសក្តិសមបំផុតនាពេលបច្ចុប្បន្ន និងចូលរួមដល់ការអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា។

- រង្វាន់នេះនឹងចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ប្រកបដោយសមធម៌ ជាពិសេសជួយលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរួមចំណែកក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

- រង្វាន់នេះនឹងចូលរួមលើកកម្ពស់សកម្មភាពពាណិជ្ជកម្មរបស់ផ្នែកឯកជន។ ជាការពិត សហគ្រាស ឬបុគ្គលដែលទទួលបានវិញ្ញាបនបត្រទទួលស្គាល់ពានរង្វាន់ និងអេកូឡាបិលនេះនឹងជួយលើកស្ទួយមុខមាត់កេរ្តិ៍ឈ្មោះរបស់សហគ្រាស ឬបុគ្គលនោះ។ រង្វាន់នេះនឹងក្លាយជាយុទ្ធសាស្ត្រផ្សព្វផ្សាយទីផ្សារក្នុងការទាក់ទាញអតិថិជន និងជួយកាត់បន្ថយការចំណាយប្រតិបត្តិការរបស់សហគ្រាសតាមរយៈការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព(១)។

ដោយសារសេចក្តីព្រាងនេះមានលក្ខណៈខ្វះខាត អង្គប្រជុំបានសម្រេចឲ្យក្រសួងសាមី យកឯកសារនេះទៅរៀបចំឡើងវិញ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតង។

# សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៤-២០១៦

កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **តាល់ ណៃអ៊ីម** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៤-២០១៦ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រី នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។



ក្រសួងផែនការបានរៀបចំសេចក្តីព្រាងឯកសារកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៤-២០១៦ដោយផ្អែកលើស្មារតីនិងខ្លឹមសារនៃ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៤-២០១៦ (ក.វ.ស.) លើកនេះត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់កត្តាចម្បង និងស្ថានភាពជាក់ស្តែងបីសំខាន់ៗ ពោលគឺ ទី១-ការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី២ និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ទី២-តម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ (ប្រមាណជិត ៦ ៣០០ លានដុល្លារអាមេរិក) និង ទី៣-បរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលបានសន្យានៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (វ.ស.អ.ក.) កន្លងមក (ប្រមាណជិតមួយពាន់លានដុល្លារ) និងការទទួលបានហិរញ្ញប្បទានសម្រាប់អនុវត្តជាក់ស្តែងកន្លងទៅនេះ។ ក.វ.ស. បីឆ្នាំរំកិល ២០១៤-២០១៦ ដែលមានតម្លៃសរុបប្រចាំឆ្នាំ ប្រមាណ ១ ៥៣០ លានដុល្លារអាមេរិក ត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ (៦ ៣០០ លានដុល្លារអាមេរិក) ដើម្បីឲ្យបានស្របតាមស្ថានភាពជាក់ស្តែងនៃការប្រែប្រួលថ្លៃទំនិញ និងអតិផរណា ហើយក៏ផ្អែកលើបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលដៃគូអភិវឌ្ឍធ្លាប់បានសន្យានៅក្នុង វ.ស.អ.ក. កន្លងទៅនេះ (ប្រមាណជិតមួយពាន់លានដុល្លារ) ផងដែរ។

ក.ស.វ. បីឆ្នាំរំកិល ២០១៤-២០១៦ មានគម្រោងសរុបចំនួន ៤១០ ក្នុងនោះមាន ១៦២គម្រោងកំពុងដំណើរការ ដែលត្រូវការទុនចំនួន ២ ៧២៨ លានដុល្លារអាមេរិក និង ២៤៨គម្រោង ជាគម្រោងសម្រាប់អនុវត្ត ជយអជ ត្រូវការទុនចំនួន ១ ៨៦៩ លានដុល្លារអាមេរិក។ ជាសរុបសម្រាប់ ក.វ.ស. បីឆ្នាំរំកិល ២០១៤-២០១៦ ឆ្នាំ២០១៤ ចំនួន ១៦៨០ លានដុល្លារអាមេរិក ឆ្នាំ២០១៥ ចំនួន១៤៩៩ លានដុល្លារអាមេរិក និងឆ្នាំ២០១៦ ចំនួន ១៤១៨ លានដុល្លារអាមេរិក។ បរិមាណទុនសរុប ៤ ៥៩៧ លានដុល្លារអាមេរិក នៃ ក.វ.ស. បីឆ្នាំរំកិល ២០១៤-២០១៦ ក្នុងនោះបរិមាណទុនដែលសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍរួចហើយ មានចំនួន ៣ ១៤២ លានដុល្លារអាមេរិក (ក្នុងនោះពីរាជរដ្ឋាភិបាលកម្ពុជាចំនួន ៦៧៥ លានដុល្លារអាមេរិក និងពីដៃគូអភិវឌ្ឍន៍ចំនួន ២ ៤៦៧ លានដុល្លារអាមេរិក) ដោយត្រូវការទុនបន្ថែមចំនួន ១ ៤៥៥ លានដុល្លារអាមេរិក(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៤-២០១៦។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១៣*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកក្កដា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកក្កដា ឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ១,០% ធៀបនឹងខែមុន និងកើនឡើង ៤,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ កំណើនថ្លៃទំនិញប្រើប្រាស់ធៀបនឹងខែដូចគ្នាឆ្នាំមុនជាចម្បងបណ្តាលមកពីក្រុមម្ហូបអាហារ ដែលមានការរួមចំណែក ៥៣% ទៅលើការឡើងថ្លៃសរុប។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុនក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | | |
|---|---|---|---|
| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
| ម្ហូបអាហារ: +៤,៩%<br>សម្លៀកបំពាក់និងស្បែកជើង : +៥,១%<br>គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ :+៣,៩%<br>សុខាភិបាល: +៦,៣% | ការដឹកជញ្ជូន: +២,៧%<br>ការកម្សាន្ត និងវប្បធម៌ : +៥,៥%<br>ការសិក្សា : +៦,៧%<br>ភោជនីយដ្ឋាន: +៦,៣% | សាច់គោស្រស់: +១១%<br>សាច់មាន់ស្រស់: +៥,៤%<br>ត្រីស្រស់ : +៤,២%<br>ផ្លែឈើ : +៨,៤% | បន្លែ: +៩,១%<br>ឧស្ម័ន: -០,៨%<br>ប្រេងសាំង: +៨,១%<br>ប្រេងម៉ាស៊ូត: +៨,៧% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ គាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀស គាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១–២០១៣

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា[P] | កញ្ញា[P] | តុលា[P] | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៧% | ៣,៨% | ៣,៩% | | | ២,៩% |
| | ខែមុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៨% | ០,៣ | -០,១% | | | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |

P: តួលេខខែ សីហា **កញ្ញា និងតុលា** ឆ្នាំ២០១៣ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ **DECOMPOSITION**)

ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃ ទំនិញប្រើប្រាស់ ឆ្នាំ២០១១ ២០១២ និង ២០១៣ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




➡អត្រាប្តូរប្រាក់៖

| *ប្រភេទ* | កក្កដា ២០១៣ | មិថុនា ២០១៣ | កក្កដា ២០១២ | *ប្រភេទ* | កក្កដា ២០១៣ | មិថុនា ២០១៣ | កក្កដា ២០១២ |
|---|---|---|---|---|---|---|---|
| ៛/ដុល្លារ | ៤០៦២៛/១$ | ៤០៦២៛/១$ | ៤០៧០៛/១$ | បាត/ដុល្លារ | ៣១,២៦បាត/១$ | ៣១,១១បាត/១$ | ៣១,៥៨បាត/១$ |
| ៛/បាត | ១៣០៛/១បាត | ១៣១៛/១បាត | ១២៩៛/១បាត | ដុង/ដុល្លារ | ២១១៥០ដុង/១$ | ២១០០០ដុង/១$ | ២០៨៤០ដុង/១$ |
| ៛/ដុង | ០,១៩២៛/១ដុង | ០,១៩៣៛/១ដុង | ០,១៩៥៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករនិងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកក្កដា ឆ្នាំ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១.ចំណូលថវិកាជាតិ** : អនុវត្តបាន ៥៦៨,៤ពាន់លានរៀល (មធ្យមប្រចាំខែ៧០% នៃគម្រោង) ក្នុងនោះចំណូលចរន្ត ៦៦៨,៤ ពាន់លានរៀល (មធ្យមប្រចាំខែ ៩៤% នៃគម្រោង) និងពុំមានចំណូលមូលធនទេ។

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ — ២០១៣ (ពាន់លានរៀល)




- ➢ បើធៀបនឹងខែមុនចំណូលថវិកាជាតិ ថយចុះ១៦,៩% និង ថយចុះ៧,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណូល ចរន្តថយចុះ១៦,៩% ធៀបនឹងខែមុន និងថយចុះ៧,៧% *ធៀបនឹងខែដូចគ្នាឆ្នាំមុន។*
- ➢ ក្នុងចំណូលចរន្ត៖

✓ចំណូលសារពើពន្ធមានចំនួន ៥២៩,៥ ពាន់លានរៀល ថយចុះ ១២,៧% ធៀបនឹងខែមុន និងថយចុះ ៦,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៣៨,៩ពាន់លានរៀល ថយចុះ ៤៩,៧% ធៀបនឹងខែមុន និងថយចុះ ២៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -៥,៤% | (+៥,៣%) | ➢ នេសាទ: -២៣,០% | (-៧៨,៧%) |
| ➢ ចំណូលពន្ធដារ: +១,៥% | (-៧,១%) | ➢រុក្ខាប្រមាញ់ : — | (-១៧,១%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: -២៦,៦% | (-២៣,៥%) | ➢ អាកាសចរណ៍ស៊ីវិល: -៩៣,៧% | (-២៣,១%) |
| ✧ កាស៊ីណូ : -៥២,១% | (-២១,៩%) | ➢ ផលទុនទេសចរណ៍: -២៣,៣% | (+២០៣៨,៨%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៨៤,៧% | (-៨៨,០%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: +៤៤០,៩% | (-៣៣,៦%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +២៧,១% | (+០,៩%) | ➢អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): -៥៦,១% | (-៣៧,៥%) |

២.២. *ចំណាយថវិកាជាតិ៖* អនុវត្តបានចំនួន៥៦៣ពាន់លានរៀល( *មធ្យមប្រចាំខែ ៥២% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន៤៨៥ពាន់លានរៀល ( *មធ្យមប្រចាំខែ៧៣% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៧៧ ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន*ចំណាយថវិកាជាតិ ថយចុះ ០,៩% និងថយចុះ ៤២,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្ត កើនឡើង ៦,៣% ធៀបនឹងខែមុនប៉ុន្តែ ថយចុះ ៤៥,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯ ចំណាយមូលធន ថយចុះ ៣០,៦% ធៀបនឹងខែមុន និងថយចុះ ១៦,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ថវិកាជាតិនៃខែកក្កដាមានអតិរេក ៦ ពាន់លានរៀល ស្មើនឹង ១,៥ លានដុល្លារ ស.រ.អា។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដា ឆ្នាំ២០១៣ មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ M₂ មានចំនួន ៣០៣១៦ ពាន់លានរៀល ថយចុះ ៤,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៣,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការថយចុះនៃ M₂ ធៀបនឹងខែមុន ជាចម្បងបណ្តាលមកពីប្រាក់បញ្ញើជារូបិយបណ្ណថយចុះ៥,៧% ។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៨,១% នៃរូបិយវត្ថុ M₂ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨១,៩%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែកក្កដា ឆ្នាំ២០១៣



| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៧,២% | ១៧,៣% | ១៧,០% | ១៧,៣% | ១៦,៩% | ១៦,៨% | ១៨,១% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៧% | ១៣,៧% | ១៣,៩% | ១៤,០% | ១៣,៣% | ៨៣,២% | ៨១,៩% | | | | | |

បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែឧសភា២០១៣: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ មានចំនួន ៣៦០២ លានដុល្លារ កើនឡើង៤,៥% ធៀបនឹងខែមុន និង កើនឡើង ១៣,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងខែនេះមានចំនួន ៧៧៩០ ពាន់លានរៀល ថយចុះ ២០,៤% ធៀបនឹងខែមុន និងថយចុះ ១៥,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢*ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *កក្កដា ២០១៣* | *មិថុនា ២០១៣* | *កក្កដា ២០១២* |
|---|---|---|---|
| ធនាគារពាណិជ្ជ (ពាន់លានរៀល) | ២៧៥៣៧ | ២៩៤៩៤ | ២០៦១១ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ពាន់លានរៀល) | មិនទាន់មានតួលេខ | ៤៤៥៩ | ៣០៣៨ |

➢***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែកក្កដា៖

| *ប្រភេទអត្រាការប្រាក់* | *កក្កដា២០១៣* | *មិថុនា២០១៣* | *កក្កដា២០១២* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៨% | ៥,៩៨% | ៥,៧៩% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៩៣% | ១១,៩៣% | ១២,១២% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៩% | ៤,៤៣% | ៤,៤៣% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៤២% | ១១,៧១% | ១២,១១% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកក្កដាឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម៖**

✓ផលិតផលនេសាទមាន ៣៩ ពាន់តោន ថយចុះ ១៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៨៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម៖**

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា មានចំនួន ៣១០,២ GWh ថយចុះ ៤% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះវារីអគ្គិសនីមានចំនួន ១៣៣,៩ GWh កើនឡើង ១២៥% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១២,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤២៨លានដុល្លារ ស្មើនឹងខែមុន ប៉ុន្តែកើនឡើង៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន—កក្កដា ២០១៣ | ចំនួន—មិថុនា ២០១៣ | ចំនួន—កក្កដា ២០១២ |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ១៥ | ១៦ | ១៧ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១០១១ | ៩៩៦ | ៨០៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៣ | ២២ | ៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៤ | ៤ | ៧ |

➢**សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៥៥,៩ពាន់ម² ថយចុះ៨៩% ធៀបនឹងខែមុននិងថយចុះ៧៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១០៤,៩លានដុល្លារ ថយចុះ ៩៣% ធៀបនឹងខែមុន និងថយចុះ ៨០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម²—កក្កដា២០១៣ | ពាន់ម²—មិថុនា២០១៣ | ពាន់ម²—កក្កដា ២០១២ |
|---|---|---|---|
| ▪ លំនៅឋាន | ១៥៦,២ | ១០៨,៦ | ១១៧៩,២ |
| ▪ ឧស្សាហកម្ម | ១២០,៤ | ១៦,៦ | ៣៩៧,៥ |
| ▪ ពាណិជ្ជកម្ម | ២៩,៥ | ២៨៣៩,៨ | ៩,២ |
| … | | | |
| អនុញ្ញាតសរុប | ៣៥៥,៩ | ៣១២៤ | ១៦៣៩ |

✓ ដូច្នេះសំណង់ដែលពេញនិយមនាខែនេះគឺលំនៅឋាន ៤៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុប ឧស្សាហកម្ម ៣៤% និង ពាណិជ្ជកម្ម ៨% ។

➤ការងារ៖

| ប្រភេទ | នាក់ : កក្កដា២០១៣ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៧០៨ | -៤៤% | -៧៣% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៤៥១២ | +៩៤% | +១៤% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៤០៧៦ | +១៤៧% | +១៦១% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣៣៧ | -៥០% | -៨៦% |

➤វិនិយោគ៖

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)៖

| ប្រភេទ | កក្កដា២០១៣ | មិថុនា២០១៣ | កក្កដា២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៣៧,៧ | ១៨៧៤,៤ | ១៥៩,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | 0 | 0 | ៤៦,៩ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៧,៧ (១៥,៧) | ១០៤,៤ (0) | ១១២,៥ (0) |
| វិស័យទេសចរណ៍ | 0 | 0 | 0 |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | 0 | ១៧៧០ | 0 |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៦ | ១៦ | ២០ |
| បង្កើតការងារ (ពាន់នាក់) | ៧,៧ | ៣៦,៩ | ៣១,៣ |

➤សេវាកម្ម និងទេសចរណ៍៖

✓ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—កក្កដា ២០១៣ | ចំនួន—មិថុនា ២០១៣ | ចំនួន—កក្កដា២០១២ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣១៨ | ២៨៤ | ២៩៥ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៣ | ១ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ២៨២ | ២១១ | ២២៥ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៥៩០ពាន់តោន កើនឡើង ១៥% ធៀបនឹងខែមុន និង កើនឡើង ២៧% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: -១១% | (-១៨%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +៥៥% | (+១៧៧%) |
| ▪ កំពង់ផែកំពង់សោម: +១០% | (+២៣%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៤៩% | (+៦៩%) |

➢ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥,៦ | +២% | +៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៥ | +១៥% | +២៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៣០ | +១៤% | +១៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៨ | -៨% | +៣% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៣៩ | +១២% | +១៩% |
| ✓ តាមផ្លូវអាកាស | ១៤៥ | +១៤% | +១៤% |
| ✓ តាមផ្លូវគោក និងទឹក | ១៩៤ | +១១% | +២៣% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលខែកក្កដាមានចំនួន ១៧៦៨ពាន់លានរៀល (៤៤១,៩លានដុល្លារ) ថយចុះ ៤៩% ធៀបនឹងខែមុន និងថយចុះ ៣២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១០% | -២៣% | រថយន្តសរុប (ព.ល.រ) | -១១% | +៧% |
| ប្រេងម៉ាស៊ូត | +១៤% | +១២% | រថយន្តសរុប (គ្រឿង) | +៧% | +២% |
| ឧស្ម័ន | -៣១% | -៤១% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -១៩% | +១១៩% |
| អគ្គិសនីនាំចូល | -២១% | -២% | ម៉ូតូ (គ្រឿង) | -៧% | +៣៦% |
| ដែកសំណង់ | +២% | -២៨% | អង្ករ | -៨១% | -៩៧% |
| ស៊ីម៉ងត៍ | -១% | -៣០% | ផ្លែឈើនិងបន្លែ | +៦% | +៧៥% |
| គ្រឿងអេឡិចត្រូនិក | +៥៣% | +៩% | ជីនិងថ្នាំកសិកម្ម | -៣៦% | -១% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៩% | +២២% |

➡ **ការនាំចេញ**ខែកក្កដាឆ្នាំ២០១៣ មានចំនួន ២៤៩៣ ពាន់លានរៀល ស្មើនឹង៦២៣,២លានដុល្លារ ស.រ.អា. (១៤១% នៃការនាំចូល) ថយចុះ ២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ មុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១២៦% | +២១៩% | ផលិតផលនេសាទ | +១៣% | -៦៤% |
| វាយនភណ្ឌនិងស្បែកជើង | -២% | +១៥% | កៅស៊ូ | +១៩% | +២៩% |
| អង្ករ | -៨% | +៧៥% | | | |

➡ក្នុងខែកក្កដានេះជញ្ជីងពាណិជ្ជកម្មមានអតិរេកចំនួន៧២៥ពាន់លានរៀល ស្មើនឹង១៨១លានដុល្លារ ស.រ.អា.។



## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ពន្ធលើប្រាក់ចំណេញ | -៥,៩% | -៣៦,១% | — |
| ២ | ចំណូលកាស៊ីណូ | -៥២,១% | -២១,៩% | — |
| ៣ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -៨៤,៧% | -៨៨,០% | — |
| ៤ | ចំណូលមិនមែនសារពើពន្ធ | -៤៩,៧% | -២៦,៣% | — |
| ៥ | សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ម²) | -៨៩% | -៧៨% | — |
| ៦ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. (លានដុល្លារ) | -៩៨% | -៧៦% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

*សេចក្តីសន្និដ្ឋាន៖*

ការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជន នឹងប៉ះពាល់យ៉ាងច្រើនលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនាឆមាសទី២ ឆ្នាំ២០១៣នេះ។ លទ្ធផលចំពោះមុខ ដែលបង្ហាញក្នុងខែកក្កដាគឺ៖

ក) ចំណូលថវិកាជាតិមានការថយចុះ ជាចម្បងបណ្តាលមកពីការថយចុះនៃពន្ធគយ

ខ) វិស័យសំណង់ និងលំហូរទុនវិនិយោគបរទេសមកកម្ពុជា មានការថយចុះយ៉ាងខ្លាំង

គ) ការនាំចូលមានការថយចុះ ។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៨/០៨/១៣<br>ម៉ោង ១០ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **កែវ រ៉េមី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ២ | ១៦/០៨/១៣<br>ម៉ោង ០៨ : ០០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីជូនភ្លើងបូជាសព ឯកឧត្តម **កែវ សាផល** នៅវត្តទួលទំពូង រាជធានីភ្នំពេញ។ |
| ៣ | ១៩/០៨/១៣<br>ម៉ោង ១០: ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូ ដឹកនាំដោយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នឹងអញ្ជើញទៅចូលរួមសន្និសីទពិសេស ស្តីពីចលនាមិនប្រក្រតីរបស់ប្រជាជននៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៤ | ២០/០៨/១៣<br>ម៉ោង ០៩ : ០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយផ្លូវជាតិលេខ៦ ចាប់ពីភ្លើងស្តុបសណ្ឋាគារសុខាអង្គរ ដល់អាកាសយានដ្ឋានខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ២០/០៨/១៣<br>ម៉ោង ១៦ : ៤០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីទទួលដំណើរគណៈប្រតិភូ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត សភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នឹងធ្វើដំណើរមកមាតុភូមិនិវត្តន៍ជាផ្លូវការពីទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៦ | ២៦/០៨/១៣<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាអធិបតី ក្នុងការប្រជុំជាមួយឯកឧត្តម **ឃឹម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ដើម្បីពិគ្រោះយោបល់ និងដោះស្រាយលើផលប៉ះពាល់សម្រាប់ការងារស្តារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយផ្លូវជាតិលេខ៦ ចាប់ពីភ្លើងស្តុបសណ្ឋាគារសុខាអង្គរ ដល់ព្រលានយន្តហោះយោធាខេត្តសៀមរាប នៅសាលាខេត្តសៀមរាប។ |
| ៧ | ២៦/០៨/១៣<br>ម៉ោង ១៨ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងដែលរៀបចំឡើងដោយ លោកជំទាវ Bu Jianguo ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពថ្មី នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគាររអាំងទៃរកុងទីណង់តាល់។ |
| ៨ | ២៩/០៨/១៣<br>ម៉ោង ០៩ : ៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក Geoffroy Auzou (សមាគមបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ) នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ២៩/០៨/១៣<br>ម៉ោង ១៥ : ៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡៃន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ង៉ាន់ ភិរុណ | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្កដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in